យន្តការផ្សព្វផ្សាយជាតិគាំពារសង្គម

# កម្រងឯកសារ

# ស្តីពី

# របប និងកម្មវិធីសំខាន់ៗនៃប្រព័ន្ធគាំពារសង្គម

សហការអនុវត្តដោយ

គាំទ្រថវិកាដោយ

# ១. អំពីប្រព័ន្ធគាំពារសង្គមកម្ពុជា






គាំពារ សង្គម កម្ពុជា
SOCIAL PROTECTION IN CAMBODIA

# ប្រព័ន្ធគាំពារសង្គម

*ប្រព័ន្ធគាំពារសង្គម*
*សំដៅដល់ គោលនយោបាយ កម្មវិធី សកម្មភាព រួមទាំងក្របខ័ណ្ឌគតិយុត្តិ និងស្ថាប័ន ដែលត្រូវបានរៀបចំឡើង ដើម្បីផ្តល់ការគាំពារ និងពង្រឹងសមត្ថភាពរបស់សមាជិកក្នុងសង្គមកម្ពុជា ក្នុងការឆ្លើយតបចំពោះហានិភ័យសេដ្ឋកិច្ច និងភាពងាយរងគ្រោះមួយចំនួន ដែលកើតឡើងពីការប្រែប្រួលលក្ខខណ្ឌរស់នៅ និងការងារ។*

**ប្រព័ន្ធជំនួយសង្គម**



**ប្រព័ន្ធសន្តិសុខសង្គម**



**ប្រព័ន្ធគាំពារសង្គមដែលមានលក្ខណៈ ប្រមូលផ្តុំ សង្គតិភាព និងប្រសិទ្ធភាព**

# ១. អំពីប្រព័ន្ធគាំពារសង្គមកម្ពុជា

## ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម

### ប្រព័ន្ធសន្តិសុខសង្គម

- សោធន
- ការថែទាំសុខភាព
- ហានិភ័យការងារ
- និកម្មភាព

### ប្រព័ន្ធជំនួយសង្គម

- ការឆ្លើយតបនឹងគ្រោះអាសន្ន
- ការអភិវឌ្ឍមូលធនមនុស្ស
- ការបណ្តុះបណ្តាលវិជ្ជាជីវៈ
- សុខុមាលភាពសម្រាប់ជនងាយរងគ្រោះ

បទបង្ហាញស្តីពី

# យន្តការនៃការអនុវត្តកម្មវិធី
# ឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

# ២. លក្ខខណ្ឌនៃការចុះឈ្មោះ



ឬ





ស្ត្រីអ្នកទទួលផល

កុមារអ្នកទទួលផល
ដែលម្ដាយបានចុះឈ្មោះ

កុមារអ្នកទទួលផល
ដែលម្ដាយមិនបានចុះឈ្មោះ

# ៣. ដំណាក់កាល និងកាលវិភាគនៃការបើកផ្តល់

| ដំណាក់កាល | សេវាពិនិត្យសុខភាព | ពេលវេលាទទួលសេវា | ការបើកផ្តល់ |
|---|---|---|---|
| ដំណាក់កាលទី១ | ការពិនិត្យផ្ទៃពោះលើកទី១ | គភ៌មានអាយុតិចជាង១២សប្តាហ៍ | ៤០.០០០រៀល |
|  | ការពិនិត្យផ្ទៃពោះលើកទី២ | គភ៌មានអាយុ២០ទៅ២៤សប្តាហ៍ | ៤០.០០០រៀល |
| | ការពិនិត្យផ្ទៃពោះលើកទី៣ | គភ៌មានអាយុ៣០ទៅ៣២សប្តាហ៍ | ៤០.០០០រៀល |
| | ការពិនិត្យផ្ទៃពោះលើកទី៤ | គភ៌មានអាយុ៣៦ទៅ៣៨សប្តាហ៍ | ៤០.០០០រៀល |
| ដំណាក់កាលទី២ | សម្រាលកូន | តាមកាលវេលាជាក់ស្តែង | ២០០.០០០រៀល |
|  | ការពិនិត្យក្រោយសម្រាលលើកទី១ ( ពិនិត្យទាំងម្តាយទាំងកូន ) | ថ្ងៃទី៧ ក្រោយសម្រាល | ៤០.០០០រៀល |
| | ការពិនិត្យក្រោយសម្រាលលើកទី២ ( ពិនិត្យទាំងម្តាយទាំងកូន ) | ថ្ងៃទី១៤ ក្រោយសម្រាល | ៤០.០០០រៀល |
| | ការពិនិត្យក្រោយសម្រាលលើកទី៣ ( ពិនិត្យទាំងម្តាយទាំងកូន ) | កូនមានអាយុ១ខែកន្លះ | ៤០.០០០រៀល |
| | ការពិនិត្យក្រោយសម្រាលលើកទី៤ ( ពិនិត្យសុខភាពកូន ) | កូនមានអាយុ២ខែកន្លះ | ៤០.០០០រៀល |
| ដំណាក់កាលទី៣ | ការពិនិត្យក្រោយសម្រាលលើកទី៥ ( ពិនិត្យសុខភាពកូន ) | កូនមានអាយុ៣ខែកន្លះ | ៤០.០០០រៀល |
|  | ការពិនិត្យក្រោយសម្រាលលើកទី៦ ( ពិនិត្យសុខភាពកូន ) | កូនមានអាយុ៦ខែ | ៤០.០០០រៀល |
| | ការពិនិត្យក្រោយសម្រាលលើកទី៧ ( ពិនិត្យសុខភាពកូន ) | កូនមានអាយុ៩ខែ | ៤០.០០០រៀល |
| | ការពិនិត្យក្រោយសម្រាលលើកទី៨ ( ពិនិត្យសុខភាពកូន ) | កូនមានអាយុ១២ខែ | ៤០.០០០រៀល |
| | ការពិនិត្យក្រោយសម្រាលលើកទី៩ ( ពិនិត្យសុខភាពកូន ) | កូនមានអាយុ១៨ខែ | ៤០.០០០រៀល |
| | ការពិនិត្យក្រោយសម្រាលលើកទី១០ ( ពិនិត្យសុខភាពកូន ) | កូនមានអាយុ២៤ខែ | ៤០.០០០រៀល |

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

# ៤. ការចុះឈ្មោះ និងការបើកផ្តល់លើកដំបូង



- ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ ត្រូវយកប័ណ្ណសមធម៌ ឬប័ណ្ណអាទិភាព និងសៀវភៅសុខភាព មាតា ឬប័ណ្ណសុខភាពកុមារ ទៅចុះឈ្មោះ នៅឃុំ សង្កាត់ណាមួយ





- អ្នកទទួលបន្ទុកកម្មវិធីបញ្ចូលព័ត៌មានអ្នកទទួលផល
- មេឃុំ សង្កាត់ផ្ទៀងផ្ទាត់ និង អនុម័តការចុះឈ្មោះចូលកម្មវិធី

Wing

- ស្ថាប័នបើកផ្តល់ផ្ទេរសាច់ប្រាក់ចូលគណនីធនាគារនិងផ្តល់ការបើកប្រាក់ជូនអ្នកទទួលផល



- អ្នកទទួលផលអាចដកប្រាក់ពីភ្នាក់ងារបើកប្រាក់ណាមួយ

(+855) 23 890 666
www.nspc.gov.kh
គាំពារសង្គមកម្ពុជា
Camnspc

SOCIAL PROTECTION IN CAMBODIA

## បទបង្ហាញស្តីពី

# កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

# ៣. អំពីការអនុវត្តកម្មវិធី

**លក្ខខណ្ឌទទួលផល**

- **មានប័ណ្ណសមធម៌ ដែលមានសុពលភាព** ដោយឈរលើកម្រិតភាពក្រីក្រះ ក្រកម្រិត១ ឬក្រកម្រិត ២ និង



- បានទៅ**ផ្ទៀងផ្ទាត់បញ្ជីឈ្មោះ**នៃកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ ក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ នៅសាលាឃុំ សង្កាត់ណាមួយ។



# ៣. អំពីការអនុវត្តកម្មវិធី

## ការបើកផ្ដល់លើកដំបូង




Wing





- សមាជិកគ្រួសារក្រីក្រត្រូវទៅឃុំ សង្កាត់ ដើម្បីចុះឈ្មោះ ដោយយកមកជាមួយនូវប័ណ្ណសមធម៌
- ឃុំ សង្កាត់ត្រូវចុះឈ្មោះអ្នកទទួលផល ដោយបញ្ចូលលេខប័ណ្ណសមធម៌ក្នុងអែប និងអនុម័ត
- ភ្នាក់ងារបើកផ្ដល់បញ្ចូលលេខប័ណ្ណសមធម៌ ឬ ប័ណ្ណអាទិភាព ក្នុងប្រព័ន្ធ រួចផ្ដល់ការបើកផ្ដល់ដល់អ្នកទទួលផល
- អ្នកទទួលផលទទួលបានសាច់ប្រាក់ពីភ្នាក់ងារបើកប្រាក់។

# ៣. អំពីការអនុវត្តកម្មវិធី

## ការបើកផ្តល់ប្រចាំខែ





Wing







- បន្ទាប់ពីបានចុះឈ្មោះរួច អ្នកទទួលផលទៅបើកប្រាក់ឧបត្ថម្ភប្រចាំខែ នៅភ្នាក់ងារវីង ដោយយកមកជាមួយនូវប័ណ្ណសមធម៌
- ភ្នាក់ងារវីង បញ្ចូលលេខប័ណ្ណសមធម៌ ក្នុងប្រព័ន្ធ រួចផ្តល់ការបើកផ្តល់ដល់អ្នកទទួលផល
- អ្នកទទួលផលទទួលបានសាច់ប្រាក់ពីភ្នាក់ងារបើកប្រាក់។

# ៣. អំពីការអនុវត្តកម្មវិធី

## ៣. ប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ នៅទីជនបទ

| ល.រ. | ប្រភេទមុខសញ្ញាក្រុមជនគោលដៅ | ប្រាក់ឧបត្ថម្ភក្នុងមួយខែ តាមកម្រិតក្រីក្រ | |
|---|---|---|---|
| | | ក្រីក្រ១ | ក្រីក្រ២ |
| ១ | គ្រួសារមានប័ណ្ណសមធម៌ (ប្រភេទ ១ និងប្រភេទ ២) | ៨០ ០០០ រៀល | ៨០ ០០០ រៀល |
| ២ | សមាជិកគ្រួសារក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៣ | កុមារអាយុពី០-៥ឆ្នាំក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៤ | ជនមានពិការភាពក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៥ | មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងក្នុងម្នាក់ៗ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |
| ៦ | គ្រួសារក្រីក្រដែលមានសមាជិកផ្ទុកមេរោគអេដស៍ | ២៤ ០០០ រៀល | ១៦ ០០០ រៀល |




## អាចស្វែងយល់បន្ថែមតាមរយៈ:

## គេហទំព័រ https://nspc.gov.kh

## ឬ ទំព័របណ្តាញសង្គម Facebook “គាំពារសង្គមកម្ពុជា - Social Protection in Cambodia”



# បទបង្ហាញស្តីពី
# ការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ

# ១. និយមន័យគ្រួសារក្រីក្រ

## តើគ្រួសារសម្រាប់អត្តសញ្ញាណកម្មគ្រួសារក្រីក្រមានន័យយ៉ាងដូចម្តេច?



គ្រួសារសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រមានន័យថា៖

- មនុស្សដែលហូប (ញ៉ាំ) បាយឆ្នាំងតែមួយ ឬចំណាយលើម្ហូបអាហាររួមជាមួយគ្នា
- គ្រួសារអាចរាប់បញ្ចូលទាំងបុគ្គល (នៅលីវ ពោះម៉ាយ មេម៉ាយ) ទាំងក្រុមមនុស្ស ដែលរស់នៅជាមួយគ្នាចាប់ពី ២នាក់ឡើងទៅ (អាចជាសាច់ញាតិ ឬមិនមែនជាសាច់ញាតិ)
- អាចរាប់ថាជាសមាជិកគ្រួសារបានលុះត្រាតែរស់នៅជាប្រចាំក្នុងគ្រួសារ ឬទើបតែអវត្តមានពីគ្រួសារតិចជាង ៦ខែ
- មេភូមិទទួលស្គាល់ថាជាគ្រួសារប្រជាពលរដ្ឋក្នុងភូមិ។

# ២. ផលប្រយោជន៍នៃបណ្ណសមធម៌





## ផលប្រយោជន៍នៃបណ្ណសមធម៌

- ការថែទាំសុខភាពដោយឥតបង់ប្រាក់នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ
- ការគាំពារសង្គមរបស់រាជរដ្ឋាភិបាល (ការឧបត្ថម្ភសាច់ប្រាក់)
- អាហារូបករណ៍ជាសាច់ប្រាក់ ឬស្បៀងអាហារនៅតាមសាលាបឋមសិក្សា
- ការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ
- ការតបណ្តាញទឹកស្អាត ឬអគ្គិសនី
- សម្ភារៈកសិកម្មផ្សេងៗ (ធុងទឹក ចប ប៉ែល គ្រាប់ពូជ ពូជសត្វចិញ្ចឹម គោយន្ត។ល។)

# ៤. នីតិវិធីស្ដីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ( ថ្មី )

តើការផ្ដល់បណ្ណសមធម៌ដំណើរការទៅយ៉ាងដូចម្ដេច?

តើខ្ញុំត្រូវធ្វើដូចម្ដេច ទើបអាចកែសម្រួលព័ត៌មាននៅក្នុងបណ្ណសមធម៌របស់ខ្ញុំបាន?

តើអ្នកកាន់បណ្ណសមធម៌អាចត្រូវបានស្នើសុំដកត្រឡប់មកវិញដែរ ឬទេ? តើដំណើរការទៅយ៉ាងដូចម្ដេច?

## នីតិវិធីស្ដីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

# សេចក្តីសង្ខេបនៃការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

## ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ

### ដំណើរការផ្តល់បណ្ណសមធម៌

- ជំហានទី ១ ការដាក់ពាក្យ និងទទួលពាក្យស្នើសុំសម្ភាសន៍
- ជំហានទី ២ ក្រុមការងារឃុំ សង្កាត់ពិនិត្យ និងសម្រេចលើពាក្យស្នើសុំសម្ភាសន៍
- ជំហានទី ៣ ក្រុមការងារឃុំ សង្កាត់ចុះសម្ភាសន៍គ្រួសារដោយប្រើឧបករណ៍ថាប្លេត
- ជំហានទី ៤ ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័តចំណាត់ថ្នាក់គ្រួសារក្រីក្រ
- ជំហានទី ៥ ការផលិត ការបោះពុម្ព និងផ្តល់បណ្ណសមធម៌

## ការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ

### ការដកគ្រួសារចេញពីបញ្ជី

- ជំហានទី ១ ការដាក់ពាក្យ និងទទួលពាក្យស្នើសុំដកគ្រួសារ
- ជំហានទី ២ ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងសម្រេចលើពាក្យស្នើសុំដកគ្រួសារ
- ដកគ្រួសារចេញតាមសំណើ ធ្វើការសម្ភាសន៍ឡើងវិញ ឬ បដិសេធពាក្យស្នើសុំដកគ្រួសារ
- ករណីសម្ភាសន៍ឡើងវិញ: ត្រូវអនុវត្តដូចជំហានទី៣ និងទី៤ ក្នុងដំណើរការផ្តល់បណ្ណសមធម៌

### ការកែសម្រួលព័ត៌មានលម្អិត

- ជំហានទី ១ ការដាក់ពាក្យ និងទទួលពាក្យស្នើសុំកែសម្រួលព័ត៌មាន
- ជំហានទី ២ ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងសម្រេចលើពាក្យស្នើសុំកែសម្រួលព័ត៌មាន
- ករណីកែសម្រួលព័ត៌មានមេគ្រួសារ: ត្រូវប្តូរបណ្ណសមធម៌ថ្មី

| ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ |
|---|
| ដំណើរការផ្តល់បណ្ណសមធម៌ |
| ដំណាក់ ១ ការដាក់ពាក្យ និងទទួលពាក្យស្នើសុំសម្ភាសន៍ |
| ដំណាក់ ២ ក្រុមការងារឃុំ សង្កាត់ពិនិត្យ និងសម្រេចលើពាក្យស្នើសុំសម្ភាសន៍ |
| ដំណាក់ ៣ ក្រុមការងារឃុំ សង្កាត់ចុះសម្ភាសន៍គ្រួសារដោយប្រើឧបករណ៍ថាប្លេត |
| ដំណាក់ ៤ ក្រុមប្រឹក្សាឃុំ សង្កាត់ពិនិត្យ និងអនុម័តចំណាត់ថ្នាក់គ្រួសារក្រីក្រ |
| ដំណាក់ ៥ ការផលិត ការបោះពុម្ព និងផ្តល់បណ្ណសមធម៌ |

## ១. ការដាក់ពាក្យ និងទទួលពាក្យស្នើសុំសម្ភាសន៍

**តើអ្នកត្រូវធ្វើដូចម្តេច ដើម្បីអាចដាក់ពាក្យស្នើសុំសម្ភាសន៍កំណត់អត្តសញ្ញាណគ្រួសារក្រីក្របាន?**

- គ្រួសារសាមីដែលគិតថាក្រីក្រអាចមកដាក់ពាក្យស្នើសុំសម្ភាសន៍តាមមធ្យោបាយ ដូចខាងក្រោម៖
    - ប្រើទម្រង់បែបបទទី២.១៖ ពាក្យស្នើសុំសម្ភាសន៍ (អាចរកបាននៅតាមសាលាឃុំ សង្កាត់) ឬ
    - ប្រើទម្រង់អេឡិចត្រូនិក/ឌីជីថល (អាចរកបាននៅលើPublic IDPoor App ឬ គេហទំព័រ https://idpoor.gov.kh)

ក្រសួងផែនការ

# ៤. នីតិវិធីស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ថ្មី)



**លក្ខណៈវិនិច្ឆ័យសម្រេច<u>សម្គាល់</u>គ្រួសារ៖**

- មានបណ្ណសមធម៌ជិតផុតសុពលភាព និងស្ថិតក្នុងស្ថានភាពជីវភាពលំបាក
- មានជីវភាពលំបាកនិងត្រូវចំណាយខ្ពស់លើសុខភាព (ជំងឺធ្ងន់ធ្ងរ ជំងឺរ៉ាំរ៉ៃ សមាជិកគ្រួសាររងគ្រោះថ្នាក់ឬធ្លាក់ខ្លួនពិការ)
- មានសមាជិកជាបង្គោលរកប្រាក់ចំណូលសម្រាប់គ្រួសារបានបាត់បង់ជីវិត
- មានសមាជិកបាត់បង់ការងារ ឬសកម្មភាពរកចំណូល ឬប្រឈមនឹង
- ការថយចុះប្រាក់ចំណូល
- រងគ្រោះដោយជំងឺរាតត្បាត ឬមហន្តរាយផ្សេងៗ (គ្រោះរាំងស្ងួត គ្រោះទឹកជំនន់ ខ្យល់ព្យុះ ។ល។)
- ទើបបង្កើតថ្មីឬលែងលះគ្នា ចេញពីគ្រួសារដែលមានបណ្ណសមធម៌មានសុពលភាព មានសមាជិកផ្ទុកមេរោគអេដស៍ ជនមានពិការភាព ស្ត្រីជាមេគ្រួសារ ចាស់ជរា
- ជនជាតិដើមភាគតិច និងគ្រួសារចល័តគ្មានទីលំនៅ។ល។

≠

**លក្ខណៈវិនិច្ឆ័យសម្រេច<u>មិនសម្គាល់</u>គ្រួសារ៖**

- មានគេហដ្ឋានឬទីលំនៅសមរម្យ ផ្ទះល្វែង ផ្ទះថ្ម។ល។
- មានទ្រព្យសម្បត្តិដែលអាចមើលឃើញដោយភ្នែកផ្ទាល់ដូចជា៖ មានរថយន្តគ្រប់ប្រភេទ ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនបញ្ចូលអាគុយ គោយន្ត ។ល។
- មានប្រាក់ចំណូលប្រសើរឡើងពីសកម្មភាពការងារ អាជីវកម្ម និងសេដ្ឋកិច្ចគ្រួសារ
- មានស្ថានភាពជីវភាពប្រសើរឡើងពីការលក់អចលនទ្រព្យ ឬជំនួយពីសាច់ញាតិ

ក្រសួងផែនការ

# សេចក្តីសង្ខេបនៃការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ



# ៤.២. ការធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ

## ៤.២.១ ការដកគ្រួសារមានជីវភាពប្រសើរចេញពីបញ្ជីគ្រួសារក្រីក្រ

### ហេតុអ្វីត្រូវមាននីតិវិធីដកបណ្ណសមធម៌មានសុពលភាព?

- ទិន្នន័យគ្រួសារក្រីក្រ ត្រូវធ្វើបច្ចុប្បន្នកម្មជាប្រចាំ
- ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធិពិនិត្យមើលស្ថានភាពជីវភាពរស់នៅរបស់គ្រួសារកាន់បណ្ណសមធម៌មានសុពលភាព និងសម្រេចដកគ្រួសារចេញពីបញ្ជីគ្រួសារក្រីក្រតាមនីតិវិធី
- គ្រួសារក្រីក្រដែលកាន់បណ្ណសមធម៌ មានសិទ្ធិស្នើសុំកែសម្រួលព័ត៌មានគ្រួសារខ្លួន។

**ការដកគ្រួសារចេញពីបញ្ជី**

↓

**ជំហានទី ១** ការដាក់ពាក្យ និងទទួលពាក្យស្នើសុំដកគ្រួសារ

↓

**ជំហានទី ២** ក្រុមប្រឹក្សាឃុំ សង្កាត់ ពិនិត្យ និងសម្រេចលើពាក្យស្នើសុំដកគ្រួសារ

↓

ដកគ្រួសារចេញតាមសំណើ ធ្វើការសម្ភាសន៍ឡើងវិញ ឬបដិសេធពាក្យស្នើសុំដកគ្រួសារ

↓

**ករណីសម្ភាសន៍ឡើងវិញ** ត្រូវអនុវត្តដូចជំហានទី៣ និងទី៤ ក្នុងដំណើរការផ្ដល់បណ្ណសមធម៌



# ៤.២ ការធ្វើបច្ចុប្បន្នកម្មគ្រួសារក្រីក្រ

## ៤.២.១ ការដកគ្រួសារមានជីវភាពប្រសើរចេញពីបញ្ជីគ្រួសារក្រីក្រ

- គ្រួសារដែលគិតថាខ្លួនស្ថិតក្នុងស្ថានភាពជីវភាពប្រសើរហើយ អាចដាក់ពាក្យស្នើសុំដកដោយស្ម័គ្រចិត្ត ឬអ្នកពាក់ព័ន្ធអាចជួយបំពេញពាក្យស្នើសុំដកគ្រួសារបាន។
- ក្រុមប្រឹក្សាឃុំ សង្កាត់ មានសិទ្ធពិនិត្យមើលស្ថានភាពជីវភាពរស់នៅរបស់គ្រួសារកាន់បណ្ណសមធម៌មានសុពលភាពដើម្បីធ្វើបច្ចុប្បន្នកម្មទិន្នន័យគ្រួសារក្រីក្រ

- អ្នកពាក់ព័ន្ធដូចខាងក្រោម អាចចូលរួមដំណើរការដកគ្រួសារដែលមានជីវភាពប្រសើរចេញពីបញ្ជីគ្រួសារក្រីក្រ៖
  - រដ្ឋបាលក្រុង ស្រុក ខណ្ឌ
  - អាជ្ញាធរមូលដ្ឋាន (រដ្ឋបាលឃុំ សង្កាត់ គណៈកម្មាធិការនានា ថ្នាក់ដឹកនាំភូមិ)
  - នាយកសាលា គ្រូបង្រៀន
  - ប្រធាន/អនុប្រធានមណ្ឌលសុខភាព បុគ្គលិកសុខាភិបាល
  - នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់
  - ក្រុមការងារពាក់ព័ន្ធនឹងកិច្ចការសង្គម (ក្រុមការងារគាំពារសង្គម ក្រសួង/មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង/មន្ទីរពាក់ព័ន្ធនានា...)
  - តំណាងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល អ្នកដឹកនាំសាសនា និងតំណាងសហគមន៍ (ដូចជា CAF) ដែលធ្វើការក្នុងឃុំ សង្កាត់។ ល។



# ៤.២ ការធ្វើបច្ចុប្បន្នកម្មគ្រួសារក្រីក្រ

## ៤.២.១ ការដកគ្រួសារមានជីវភាពប្រសើរចេញពីបញ្ជីគ្រួសារក្រីក្រ

<u>លក្ខណៈវិនិច្ឆ័យសម្រេចដកគ្រួសារ</u> ៖

- គ្រួសារមានគេហដ្ឋានឬទីលំនៅសមរម្យ ផ្ទះល្វែង ផ្ទះថ្ម ។ល។
- គ្រួសារមានទ្រព្យសម្បត្តិដែលអាចមើលឃើញដោយភ្នែកផ្ទាល់ដូចជា ៖ មានរថយន្តគ្រប់ប្រភេទ ម៉ាស៊ីនបោកស្រូវ ម៉ាស៊ីនកិនស្រូវ ម៉ាស៊ីនបញ្ចូលអាគុយ គោយន្ត ។ល។
- គ្រួសារមានប្រាក់ចំណូលប្រសើរឡើងពីសកម្មភាពការងារ អាជីវកម្ម និងសេដ្ឋកិច្ចគ្រួសារ
- គ្រួសារដែលមានស្ថានភាពជីវភាពប្រសើរឡើងពីការលក់ អចលនទ្រព្យ ឬជំនួយពីសាច់ញាតិ

តើគ្រួសារមានលក្ខណៈវិនិច្ឆ័យ យ៉ាងដូចម្តេចខ្លះ ទើបក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចដកបណ្ណសមធម៌ ?



## ៤.២ ការធ្វើបច្ចុប្បន្នកម្មគ្រួសារក្រីក្រ

### ៤.២.២ ការកែសម្រួលព័ត៌មានលម្អិត

- ស្ថានភាពព័ត៌មានគ្រួសារនីមួយៗមានការប្រែប្រួលជាប្រចាំ ដូចជា៖
  - ការកើន ឬការថយសមាជិកគ្រួសារ
  - ការប្រែប្រួលស្ថានភាពមានពិការភាពឬមានផ្ទុកមេរោគអេដស៍
  - ការខុសឈ្មោះ អាយុ ភេទរបស់សមាជិកគ្រួសារ និង
  - ការផ្លាស់ប្ដូរមេគ្រួសារ
  - លើសឬខ្វះសមាជិក។ល។



# ៤.២ ការធ្វើបច្ចុប្បន្នកម្មគ្រួសារក្រីក្រ

## ៤.២.២ ការកែសម្រួលព័ត៌មានលម្អិត

- គ្រួសារសាម៉ីដែលគិតថាស្ថានភាពព័ត៌មានគ្រួសារមានការប្រែប្រួល អាចដាក់ពាក្យស្នើសុំកែសម្រួលព័ត៌មានដោយខ្លួនឯង ឬអ្នកពាក់ព័ន្ធអាចជួយបំពេញពាក្យស្នើសុំកែសម្រួលព័ត៌មានគ្រួសារបាន។

**អ្នកពាក់ព័ន្ធដូចខាងក្រោមចូលរួមដំណើរការកែសម្រួលព័ត៌មានគ្រួសារ៖**

- រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- អាជ្ញាធរមូលដ្ឋាន (រដ្ឋបាលឃុំ សង្កាត់ គណៈកម្មាធិការនានា ថ្នាក់ដឹកនាំភូមិ)
- នាយកសាលា គ្រូបង្រៀន
- ប្រធាន/អនុប្រធានមណ្ឌលសុខភាព បុគ្គលិកសុខាភិបាល
- នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ/សង្កាត់
- ក្រុមការងារពាក់ព័ន្ធនឹងកិច្ចការសង្គម (ក្រុមការងារគាំពារសង្គម ក្រសួង/មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួង/មន្ទីរពាក់ព័ន្ធនានា...)
- តំណាងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល អ្នកដឹកនាំសាសនា និងតំណាងសហគមន៍ (អ្នកសម្របសម្រួលគណនេយ្យភាពសហគមន៍) ដែលធ្វើការក្នុងឃុំ សង្កាត់ ។ល។

ក្រសួងផែនការ

# ៤. នីតិវិធីស្ដីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ( ថ្មី )



## ៤.២ ការធ្វើបច្ចុប្បន្នកម្មគ្រួសារក្រីក្រ

### ៤.២.២ ការកែសម្រួលព័ត៌មានលម្អិត

- ការដាក់ពាក្យស្នើសុំកែសម្រួលព័ត៌មានមាន មធ្យោបាយដូចខាងក្រោម៖
  - ប្រើទម្រង់បែបបទទី២.៣៖ ពាក្យស្នើសុំកែសម្រួលព័ត៌មានគ្រួសារ (អាចរកបាននៅសាលាឃុំ សង្កាត់ ) ឬ
  - ប្រើទម្រង់អេឡិចត្រូនិក/ឌីជីថល (អាចរកបាននៅលើ Public IDPoor App ឬ គេហទំព័រ https://idpoor.gov.kh )

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

# បទបង្ហាញស្តីពី
# ការកំណត់អត្តសញ្ញាណកម្មគ្រួសារងាយរងហានិភ័យ
# ដើម្បីឆ្លើយតបនឹងសម្ពាធអតិផរណា

គាំពារ សង្គម កម្ពុជា
SOCIAL PROTECTION IN CAMBODIA

# គ្រួសារងាយរងហានិភ័យ សំដៅលើគ្រួសារ ដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ ហើយយ៉ាងហោចណាស់ មានភាពងាយរងគ្រោះមួយក្នុងចំណោម ៥ ខាងក្រោម ៖





១ សមាជិកយ៉ាងតិចម្នាក់ មានពិការភាព

២ មានសមាជិកអាយុស្មើ ឬលើស ៦០ឆ្នាំ







៣ មានកុមារតូច អាយុតិចជាង ២ឆ្នាំ

៤ សមាជិកជាកុមារ អាយុក្រោម ១៨ឆ្នាំទាំងអស់

៥ មេគ្រួសារជាស្ត្រី នៅម្នាក់ឯង ឬមេម៉ាយ

គាំពារសង្គមកម្ពុជា NSPC.GOV.KH

# គ្រួសារងាយរងហានិភ័យ ?

គ្រួសារងាយរងហានិភ័យ សំដៅលើគ្រួសារដែលរស់នៅក្បែរបន្ទាត់នៃភាពក្រីក្រ និងដែលមានភាពងាយរងគ្រោះយ៉ាងហោចណាស់ចំនួនមួយ។



# បទបង្ហាញស្តីពី
# ការកំណត់អត្តសញ្ញាណកម្មពិការភាព តាមគំរូសង្គម
# និងសិទ្ធិជាមូលដ្ឋាន

# ១. ២ គោលបំណង








**ការកំណត់អត្តសញ្ញាណពិការភាពមានគោលបំណង ៖**

១. រៀបចំប្រព័ន្ធបច្ចេកវិទ្យាគ្រប់គ្រងព័ត៌មានពិការភាព ផ្អែកតាមបទដ្ឋានអត្តសញ្ញាណពិការភាពមួយជាក់លាក់ សម្រាប់ជាមូលដ្ឋានកំណត់តម្រូវការ ក្នុងការលើកកម្ពស់សេវាគាំពារ និងការអភិវឌ្ឍ ជនមានពិការភាព ដើម្បីឆ្លើយតបនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់រាជរដ្ឋាភិបាល។

២. ផ្តល់ប័ណ្ណសម្គាល់ពិការភាពដើម្បីបង្កលក្ខណៈងាយស្រួលដល់ជនមានពិការភាពឱ្យទទួលបានសេវានានាប្រកប ដោយសមធម៌ និងបរិយាបន្នស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

# ១.៤ ប័ណ្ណសម្គាល់ពិការភាព

☞ ប័ណ្ណសម្គាល់ពិការភាពផ្តល់ដោយឥតគិតថ្លៃ គ្រប់វ័យមានពិការភាព ហើយបានចូលរួមដំណើរការកំណត់អត្តសញ្ញាណពិការភាព និងមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់។



- **ប័ណ្ណសម្គាល់ពិការភាព មានពកម្រិត ៖**
  - កម្រិតទី១ ធ្ងន់(ធ្ងន់បំផុត និងកម្រិតធ្ងន់)
  - កម្រិតទី២ មធ្យម
  - កម្រិតទី៣ ស្រាល
- **ការលុបទិន្នន័យប័ណ្ណសម្គាល់ពិការភាពលុះត្រាតែ ៖**
  - ទទួលមរណភាព
  - ចាកចេញពីកម្មវិធីដោយស្ម័គ្រចិត្ត
  - ជាសះស្បើយ(មិនមានពិការភាព)
  - ការក្លែងបន្លំអត្តសញ្ញាណពិការភាព។

# ១.៥ សារប្រយោជន៍នៃប័ណ្ណសម្គាល់ពិការភាព




របបគោលនយោបាយ តាមលក្ខណៈ
វិនិច្ឆ័យពិការភាព និងភាពក្រីក្រ




អាទិភាពការងារ
( ស្ថាប័នរដ្ឋ២% និងវិស័យឯកជន១% )



សេវាធ្វើដំណើរសាធារណៈ



ចូលទស្សនាទីកម្សាន្តសាធារណៈ
ដូចជា ទីរមណីយដ្ឋាន



ពិនិត្យសុខភាពនៅមូលដ្ឋានសុខាភិបាល
សាធារណៈ និងមណ្ឌលស្តារកាយសម្បទា




ចូលរួមសកម្មភាពសិល្បៈ កីឡា
និងវប្បធម៌ជាតិ និងអន្តរជាតិ




ទទួលបានការលើកទឹកចិត្ត
ផ្នែកពន្ធដារ



សេវាផ្សេងៗទៀត។

# ២.៤ រដ្ឋបាលឃុំ សង្កាត់



**រដ្ឋបាលឃុំ សង្កាត់មានតួនាទី និងភារកិច្ច ៖**







- ផ្សព្វផ្សាយដល់ជនមានពិការភាពឱ្យចូលរួម
- សម្ភាសន៍ជនមានពិការភាព បញ្ចូល និងបញ្ជូនទិន្នន័យមកមន្ទីរ ស.អ.យ.
- ត្រួតពិនិត្យ និងដោះស្រាយបញ្ហាពាក់ព័ន្ធ
- ប្រគល់ប័ណ្ណសម្គាល់ពិការភាពដល់ជនមានពិការភាព
- រាយការណ៍វឌ្ឍនភាព និងបញ្ហាដល់ក្រុង ស្រុក ខណ្ឌ និងមន្ទីរ ស.អ.យ
- ធ្វើបច្ចុប្បន្នភាព និងរៀបចំអត្តសញ្ញាណពិការភាពតាមការស្នើសុំ។

# មូលនិធិសមធម៌សុខាភិបាល

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

# តើអ្វីទៅ ជាមូលនិធិសមធមិសុខាភិបាល?

- យន្តការហិរញ្ញប្បទានផ្នែកគាំពារសុខភាពសង្គមដើម្បីផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋនៃគ្រួសារក្រីក្រ និង ក្រុមពលរដ្ឋគោលដៅមួយចំនួន**ទទួលបាន ឬ ប្រើប្រាស់សេវាថែទាំសុខភាពដោយឥតបង់ថ្លៃ**នៅមូលដ្ឋានសុខាភិបាលសាធារណៈ
- គិតត្រឹមពាក់កណ្តាលឆ្នាំ២០២១, មូលនិធិសមធមិ បានគ្របដណ្តប់លើ**ប្រជាពលរដ្ឋសរុបប្រមាណជាង ២.៨ លាននាក់**។
- ហិរញ្ញប្បទានសម្រាប់ទ្រទ្រង់មូលនិធិនេះ **គឺជាថវិកាបដិភាគរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍** (សម្រាប់ក្រីក្រ **គឺ បដិភាគ តែសម្រាប់ក្រៅប្រព័ន្ធ គឺ ថវិកាជាតិទាំងស្រុង)**។ ផ្អែកតាមយុទ្ធសាស្ត្រហិរញ្ញប្បទានសុខាភិបាល រាជរដ្ឋាភិបាលនឹងទទួលបន្ទុកទាំងស្រុងលើហិរញ្ញប្បទានទ្រទ្រង់មូលនិធិសមធមិសុខភាពនេះ នាពេលអនាគតខាងមុខ។
- ក្នុងឆ្នាំ ២០២២ រាជរដ្ឋាភិបាលបាន**គ្រោងថវិកាជាតិ ៧០ ០០០ លាន រៀល (ឬ ជាង ១៧លាន ដុល្លារ)** សម្រាប់ការចំណាយលើមូលនិធិនេះ។

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚៚

**ប័ណ្ណសមធម៌**

| ប័ណ្ណនេះឥតគិតថ្លៃ | លេខកូដ | 0 | 1 | 0 | 9 | 0 | 1 | 0 | 4 | – | 0 | 2 | 1 | 6 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ខេត្ត | | ស្រុក | | ឃុំ | | ភូមិ | | | លេខកូដគ្រួសារ | | | |

ជុំនៃការប្រមូលទិន្នន័យ 4
ថ្ងៃខែឆ្នាំចេញប័ណ្ណ 01/08/2011

| | | |
|---|---|---|
| **ខេត្ត:** បន្ទាយមានជ័យ | **ស្រុក:** ម៉ាឡៃ | |
| **ឃុំ:** បឹងបេង | **ភូមិ:** ល្វា | |
| **ឈ្មោះមេគ្រួសារ:** លឿន ព្រីន | **ភេទ:** ស្រី | **ឆ្នាំកំណើត:** 1967 |

**កំរិតភាពក្រីក្រ**
1

**ព័ត៌មានអំពីប័ណ្ណសមធម៌**

១. ប័ណ្ណនេះ ជាប័ណ្ណរបស់រាជរដ្ឋាភិបាលកម្ពុជា ផ្តល់ជូនគ្រួសារក្រីក្រមានឈ្មោះខាងលើ គ្រួសារក្រីក្ររបស់ភូមិ ដែលបានអនុម័តដោយក្រុមប្រឹក្សាឃុំ ។
២. ប័ណ្ណនេះនឹងអស់សុពលភាពក្រោយរយៈពេល ៤ឆ្នាំបន្ទាប់ពីការអនុម័តបញ្ជីគ្រួសារក្រីក្រដោយក្រុមប្រឹក្សាឃុំ ឬនៅពេលក្រសួងផែនការចេញប័ណ្ណសមធម៌ថ្មី នៅពេលធ្វើបច្ចុប្បន្នភាពបញ្ជីគ្រួសារក្រីក្រលើកក្រោយ ។
៣. មានតែសមាជិកនៃគ្រួសារដែលបានទទួលប័ណ្ណ មានសិទ្ធិប្រើប្រាស់ប័ណ្ណនេះ ។
៤. សមាជិកគ្រួសារ អាចយកប័ណ្ណនេះទៅបង្ហាញនៅមណ្ឌលសុខភាព ឬ មន្ទីរពេទ្យ ឬ នៅស្ថាប័ន និង អង្គការផ្សេងៗដែលមានការផ្តល់សេវាឬជំនួយដើម្បីអោយស្ថាប័ននិងអង្គការទាំងនោះ ពិនិត្យលទ្ធភាពផ្តល់សេវាឬជំនួយ ដល់សមាជិកគ្រួសារនោះ ។
៥. ប្រសិនបើលោក-អ្នករើសបានប័ណ្ណនេះនៅកន្លែងណាមួយ សូមយកទៅប្រគល់អោយក្រុមប្រឹក្សាឃុំនៃឃុំដែលមានបញ្ជាក់ឈ្មោះលើប័ណ្ណនេះ ឬយកទៅប្រគល់អោយមន្ទីរផែនការខេត្ត ។




ថ្ងៃខែឆ្នាំអនុម័តដោយក្រុមប្រឹក្សាឃុំ

ត្រាឃុំ

ហត្ថលេខាមេឃុំ

ឈ្មោះ

# តើបុគ្គលណាខ្លះមានសិទ្ធិទទួលបានអត្ថប្រយោជន៍ក្រោមមូលនិធិសមធម៌សុខាភិបាល?

- សមាជិកគ្រួសារត្រូវបានកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ អាចទទួលអត្ថប្រយោជន៍ពីមូលនិធិសមធម៌ តាមរយៈ**កម្មវិធីជាតិអត្តសញ្ញាណកម្មគ្រួសារក្រីក្រទុកជាមុននៃក្រសួងផែនការ។**

- គ្រួសារនីមួយៗទទួលបាន "**ប័ណ្ណសមធម៌**" មួយដោយក្នុងនោះមានលេខសម្គាល់គ្រួសារ ឈ្មោះមេគ្រួសារ រូបថតសមាជិកគ្រួសារ និងអាសយដ្ឋាន។

- ប័ណ្ណសមធម៌ មានសុពលភាពរហូតដល់ជុំបន្ទាប់នៃការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងតំបន់ដែលបានផ្ដល់ឱ្យ និង**ជាធម្មតាគឺមានរយៈពេលបីឆ្នាំ។ (សព្វថ្ងៃ MoP ធ្វើការកំណត់អត្តសញ្ញាកម្មគ្រួសារក្រីក្រតាមការស្នើសុំ)**

# តើអត្ថប្រយោជន៍អ្វីខ្លះដែលស្ថិតក្រោមមូលនិធិសមធម៌សុខាភិបាល?

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

- អត្ថប្រយោជន៍វេជ្ជសាស្ត្រ (សេវាពិគ្រោះក្រៅ, សេវាសម្រាកពេទ្យ, សេវាសម្រាល, និងការវះកាត់ នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ)
- អត្ថប្រយោជន៍មិនមែនវេជ្ជសាស្ត្រ (ថ្លៃធ្វើដំណើរ, ថ្លៃអាហារសម្រាប់អ្នកជំងឺ, និងវិភាគទានបុណ្យសព)
- សេវាមិនរួមបញ្ចូល÷

១) ជម្រើសការព្យាបាលសម្រាប់ជំងឺមហារីក រួមមានការព្យាបាលដោយសារធាតុគីមី ការព្យាបាលដោយសារធាតុវិទ្យុសកម្ម និងការព្យាបាលដោយអ័រម៉ូន

២) ការវះកាត់ប្តូរសរីរាង្គ

៣) ការវះកាត់កែសម្ផស្សសម្រាប់គោលបំណងកែលម្អរូបរាងរបស់បុគ្គលនិង/ឬការវះកាត់ដើម្បីលុបស្លាកស្នាមបង្ហាញភាពចាស់ជរា

៤) ការចាក់ម្ជុលវិជ្ជាសាស្ត្រ

៥) ការព្យាបាលបញ្ហាគ្មានកូន

៦) ការទូទាត់ថ្លៃព្យាបាលដែលមិនស្ថិតនៅក្នុងបញ្ជីឱសថសារវន្តរបស់ក្រសួងសុខាភិបាល។


បណ្ណសមាជិក ប.ស.ស
ទទួលបានការពិនិត្យ និងព្យាបាលដោយឥតគិតថ្លៃ
2980617-0806203-8
បណ្ណសម្គាល់សមាជិក ប.ស.ស សម្រាប់កម្មករនិយោជិតក្នុងប្រព័ន្ធ
1721217-0000015-9
បណ្ណសម្គាល់សមាជិក ប.ស.ស សម្រាប់ប្រធានភូមិ អនុប្រធានភូមិ សមាជិក ក្រុមប្រឹក្សាឃុំ / សង្កាត់
1641217-0004724-9
បណ្ណសម្គាល់សមាជិក ប.ស.ស សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ

# តើមូលនិធិសមធម៌សុខាភិបាល មានសារៈសំខាន់យ៉ាងដូចម្ដេចចំពោះប្រជាពលរដ្ឋ?

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA

- លើកទឹកចិត្ត**ការប្រើប្រាស់សេវាសុខាភិបាលនៅតាមមូលដ្ឋានសុខាភិបាសាធារណៈ** ជាពិសេសនៅតាមមណ្ឌលសុខភាពដែលកាលពីមុនពួកគាត់គ្មានលទ្ធភាពទទួលបានដោយសារគ្មានលទ្ធភាពបង់ប្រាក់

- ការបង់ថ្លៃសេវាពិគ្រោះ ពិនិត្យ និងព្យាបាលជំនួសប្រជាពលរដ្ឋគោលដៅដោយរាជរដ្ឋាភិបាល ប្រព័ន្ធនៃការអនុវត្តមូលនិធិសមធម៌សុខាភិបាល ចូលរួមលើកទឹកចិត្តដល់បុគ្គលិក គ្រូពេទ្យ  នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ) **បញ្ចៀសការយកប្រាក់ដោយផ្ទាល់ពីអ្នកជំងឺឡើយ**

- លើកកម្ពស់សុខភាពប្រជាពលរដ្ឋក្រីក្រ **ជួយកាត់បន្ថយចំណាយប្រាក់ហោប៉ៅលើការថែទាំសុខភាព និងបង្ការហានិភ័យនៃចំណាយលើការថែទាំសុខភាព និងព្យាបាលជំងឺ** ព្រមទាំងចូលរួមការពារការធ្លាក់ចូលទៅក្នុងភាពក្រីក្រដោយសារតម្រូវការសេវាសុខាភិបាល

គាំពារសង្គមកម្ពុជា
SOCIAL PROTECTION IN CAMBODIA



SOCIAL PROTECTION IN CAMBODIA

# សូមអរគុណ!

គាំពារ
សង្គម
កម្ពុជា

ឃ.ផ.ជ.គ.ស.

NSPBM